## រឿង បងប្រុស



និតនិងនួនជាបងប្អូនបង្កើតនឹងគ្នា ។ តាំងពីអ្នកមានគុណបានចែកឋានទៅ ជីវភាពគ្រួសារពួកគេជួបការលំបាកយ៉ាងខ្លាំង ។ និតជាបងបានសម្រេចចិត្តផ្អាកការរៀនសូត្រមួយរយៈដោយទុកឱ្យប្អូនបានសិក្សាបន្តទៀត ។ នួនខំរៀនណាស់មិនឱ្យបងខកចិត្តឡើយ ។ឯនិតវិញ ពេលទំនេរពីការងារស្រែចម្ការ គេបានចូលសិក្សានៅក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍ ។

ឆ្នាំនេះ នួនរៀននៅថ្នាក់ទី១២ ហើយបានប្រឡងជាប់ដូចប្រាថ្នា ។ ថ្ងៃមួយ នួនចង់ទៅរកការងារធ្វើ ដើម្បីជួយសម្រាលបន្ទុកបង តែនិតមិនយល់ព្រម ។ នួនសួរបង ៖

" តើយើងបានប្រាក់ពីណា ? " ។

និតឆ្លើយ ៖ " ឯងកុំបារម្ភ ! ទុកឱ្យបងជាអ្នកដោះស្រាយ " ។

រាត្រីនោះ និតនិទ្រាមិនលក់សោះ ព្រោះខ្លួនមិនដឹងទៅប្រកបរបរអ្វីដើម្បីរកបានប្រាក់ឱ្យប្អូនរៀននោះទេ ។ ពីមួយថ្ងៃទៅមួយថ្ងៃ និតចេះតែជញ្ជឹងគិតរកមុខរបរផ្សេងៗ តែនឹកមិនឃើញសោះ ។ ចំណែកនួនអាណិតបងខ្លាំងណាស់ ។ គេតាំងចិត្តថានឹងខិតខំរៀនសូត្រ ដើម្បីបានការងារធ្វើចិញ្ចឹមបងគេវិញ ។

ថ្ងៃមួយ និតនិងអ្នកភូមិខ្លះបាននាំគ្នាទៅខ្ចីប្រាក់ឥណទានពីធនាគារភូមិ យកមកធ្វើជាដើមទុនក្នុងការចិញ្ចឹមជ្រូកនិងត្រី ។ ជាលើកដំបូង និតបានត្រឹមតែរួចដើមប៉ុណ្ណោះ ។ ក្រោយមក និតបានរៀនបច្ចេកទេសចិញ្ចឹមសត្វពីមជ្ឈមណ្ឌលសិក្សាសហគមន៍ ។ ចាប់ពីពេលនោះមក និតចេះជំនាញចិញ្ចឹមសត្វច្បាស់លាស់ ។ និតអាចរកប្រាក់ឧបត្ថម្ភការសិក្សារបស់នួនដោយមិនជួបការលំបាកដូចមុនទៀតឡើយ ។

2



ក្រោយពីបញ្ចប់ការសិក្សា នួនបានចូលបម្រើការងារក្នុងក្រុមហ៊ុនមួយ នៅរាជធានីភ្នំពេញ ។ នួនសន្សំប្រាក់ខែបានមួយចំនួន ។ គេបានយកប្រាក់ទាំងនោះទៅប្រគល់ជូនបងទាំងអស់ ដើម្បីឱ្យបងបានរៀបអាពាហ៍ពិពាហ៍ ។ ចាប់ពីពេលនោះមក គ្រួសារនេះរស់នៅជាមួយគ្នាប្រកបដោយសុភមង្គល ។

### សំណួរ

១. តើនិតនិងនួនត្រូវជាអ្វីនឹងគ្នា?

២. តើនិតប្រើមធ្យោបាយអ្វី ដើម្បីឱ្យនួនបានបន្តការសិក្សា ?

៣. ហេតុអ្វីបានជានិតតស៊ូចិញ្ចឹមប្អូនឱ្យបានរៀនសូត្រ ?

៤. តើអ្នកពេញចិត្តតួអង្គនិតដែរ ឬទេ ? ហេតុអ្វី ?

៥. តើរឿងនេះ មានគំនិតអប់រំដូចម្ដេច ?

### លំហាត់

ក. ចូរប្រើវចនានុក្រមដើម្បីពន្យល់ន័យរបស់ពាក្យ ៖

បច្ចេកទេស ឥណទាន ឧបត្ថម្ភ ធនាគារ សហគមន៍ ។

ខ. ចូររកពាក្យន័យដូចមកជំនួសពាក្យដែលមានគំនូសពីក្រោមក្នុងល្បះនីមួយៗ ។

១. និតបានសម្រេចចិត្តឈប់រៀន ដោយទុកឱ្យនួនបានសិក្សាបន្តទៀតឡើយ ។

២. រាត្រីនេះនិតនិទ្រាមិនលក់សោះ ។

៣. និតអាចរកប្រាក់ឧបត្ថម្ភនួន ដោយមិនមានការលំបាកដូចមុនទៀត ។

៤. និតបានប្រគល់ប្រាក់ជូនបងទាំងអស់ ដើម្បីឱ្យបងបានរៀបអាពាហ៍ពិពាហ៍ ។

## ការតែងរឿងខ្លី

ចូរអ្នកសរសេររឿងខ្លីមួយ រៀបរាប់អំពីគុណរបស់បងប្រុស ឬ បងស្រីអ្នកដែលបានធ្វើចំពោះអ្នក ។